**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jul-2013, 15:40
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សារណាបន្ថែមរបស់ នួន ជា ឆ្លើយតបទៅនឹងចម្លើយតបរបស់ កសព ទៅនឹងបណ្ដឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី"**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុនីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Anta GUISSE
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ[1]។ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង[2]។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") បានដាក់បណ្តឹងសាទុក្ខរួមមួយប្រឆាំងនឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ និងចម្លើយតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[3]។ នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្តីបានដាក់សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខរបស់ខ្លួន[4]។ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងការដាក់ឯកសាររបស់មេធាវីការពារក្តី[5] ហើយមេធាវីការពារក្តីក៏បានដាក់សារណាតប[6]។

២- នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៣ មេធាវីការពារក្តីបានដាក់សារណាបន្ថែម[7] ដោយស្នើឲ្យទទួលយកព្រមទាំងនៅពេលជាមួយគ្នាដាក់អំណះអំណាងបន្ថែម និងបង្ហាញភស្តុតាងនានាដែលបានចោទប្រកាន់ពាក់ព័ន្ធទៅនឹងការទាមទាររបស់ពួកគេនៅក្នុងបណ្តឹងសាទុក្ខ។ ដូចបានរៀបរាប់ដោយមេធាវីការពារក្តី សារណាបន្ថែមគឺជុំវិញ "ទំនងជាចេតនារបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងការរកឃើញនៃ

---

[1] **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣។

[2] **E284/2/1** បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២, ១០ ឧសភា ២០១៣។

[3] **E284/4/1** បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងទៅនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាលើសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ២៧ ឧសភា ២០១៣។

[4] **E284/4/2** សារណាបន្ថែមចំពោះបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ៣០ ឧសភា ២០១៣។

[5] **E284/4/3** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, ១៧ មិថុនា ២០១៣។

[6] **E284/4/4** សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនៃសំណុំរឿង ០០២, ២៤ មិថុនា ២០១៣។

[7] **E284/4/5** សារណាបន្ថែមដើម្បីឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង, ៣ កក្កដា ២០១៣ ("សារណាបន្ថែម")។

អង្គហេតុក្នុងសំណុំរឿង០០២/០១ ដោយផ្អែកលើភស្តុតាងដែលមេធាវីការពារក្តីមិនត្រូវបានផ្តល់ឱកាសឲ្យឆ្លើយតប"[8]។

៣- អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាឆ្លើយតបដោយស្នើដល់អង្គជំនុំជម្រះតុលាការកំពូលច្រានចោលសារណាបន្ថែមនេះដោយសារមិនទាន់ដល់ពេល មិនទាន់ទុំជោរ មិនពាក់ព័ន្ធ និងគ្មានខ្លឹមសារ។ សហព្រះរាជអាជ្ញាយកឱកាសនេះកត់សម្គាល់ចំពោះកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនដែលសារបន្ថែមនេះមាន។

## II. អំណះអំណាង

### *ក. តាមពាក្យពេចន៍របស់ខ្លួន សារណាបន្ថែមនេះមិនទាន់ដល់ពេលទេ*

៤- សារណាបន្ថែមគួរបដិសេធចោល ដោយសារបញ្ហាជាលក្ខខណ្ឌតម្រូវ គឺមិនទាន់ដល់ពេល។ តាមសេចក្តីរៀបរាប់របស់មេធាវីការពារក្តីដោយផ្ទាល់ អំណះអំណាងនៃសារណាបន្ថែមនេះ គឺជុំវិញអ្វីដែលពួកគេគិតថា អង្គជំនុំជម្រះសាលាដំបូងអាចសាលក្រមក្នុងសំណុំរឿង០០២/០១។ មេធាវីការពារក្តីបានបង្ហាញសារណាបន្ថែមរបស់ខ្លួន ដោយថ្លែងថាឈរលើមូលដ្ឋាននៃការព្រួយបារម្ភដែលបានចោទប្រកាន់ចំពោះ "ភាពទំនងនៃចេតនា" និង "សញ្ញាបង្ហាញ" របស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងការរកឃើញនានារបស់អង្គជំនុំជម្រះសាលាដំបូង នឹងចេញសាលក្រមនៃសំណុំរឿង០០២/០១[9]។ ប៉ុន្តែ ការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០១ មិនទាន់ចប់ទេ ហើយក៏គ្មានសាលក្រមណាមួយបានចេញហើយដែរ។ បើសិនជាចាំបាច់ មេធាវីការពារក្តីនឹងមានឱកាសលើកជូនអង្គជំនុំជម្រះនេះ ពីអ្វីដែលអង្គជំនុំជម្រះសាលាដំបូងពិតជាបានធ្វើ នៅក្នុងបណ្តឹងសាទុក្ខមួយប្រឆាំងនឹងសាលក្រមចុងក្រោយ។ នៅពេលនោះ មេធាវីការពារក្តីអាច បើសិនជាខ្លួនជ្រើសរើស នាំយកនូវការទាមទាររបស់ខ្លួនដែលមាននៅក្នុងសារណាបន្ថែមនេះ ទាក់ទងនឹងការរំលោភសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌របស់ នួន ជា ដូចដែលខ្លួនបានអះអាង ប៉ុន្តែ ពេលវេលាមិនសមស្របទេដែលត្រូវធ្វើនៅពេលនេះ។ ការដាក់ឯកសាររបស់មេធាវីការពារក្តីនេះមិនទាន់ទុំជោរ សម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខទេ ដូច្នេះគឺមិនពាក់ព័ន្ធឡើយ។

[8] **E284/4/5** សារណាបន្ថែម, កថាខណ្ឌទី១។

[9] **E284/4/5** សារណាបន្ថែម, កថាខណ្ឌទី១។

## *ខ. សារណាបន្ថែមមានការយល់ច្រឡំ និងផ្អែកលើការបកស្រាយខុស*

៥- សារណាបន្ថែមរបស់មេធាវីការពារក្តី មិនបាននាំមកនូវព័ត៌មានពាក់ព័ន្ធថ្មីៗចំពោះអំណះអំណាងរបស់ខ្លួននៅក្នុងបណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកកិច្ចដំណើរការនីតិវិធីទេ ហើយគួរតែត្រូវបានបដិសេធចោលទាំងស្រុង ដោយមូលហេតុតែមួយគត់នេះ។ តាមពិត ដោយសារការថ្លែងខុសចំពោះច្បាប់ និងអង្គហេតុដែលមាននៅក្នុងសារណាបន្ថែម មេធាវីការពារក្តីមិនបានធ្វើអ្វីសោះក្រៅតែពីការព្យាយាមធ្វើឱ្យអង្គជំនុំជម្រះនេះយល់ច្រឡំ។

៦- សារណាបន្ថែម ដែលមានគោលដៅបង្ហាញឱ្យឃើញពី "ការបំបែកកិច្ចដំណើរការនីតិវិធីមិនអាចធ្វើអ្វីបាន"[10] នៅបន្តគូសបញ្ជាក់ពីការលាក់ពុតបែរក្រោយក្នុងនាទីចុងក្រោយរបស់មេធាវីការពារក្តីទាក់ទងទៅនឹងការបំបែកកិច្ចដំណើរការនីតិវិធី។ មេធាវីការពារក្តីថែមទាំងមិនបានរៀបរាប់តាំងពីដំបូងចំពោះការបំបែកកិច្ចដំណើរការនីតិវិធីថា "គេគ្មានមន្ទិលសង្ស័យទេថាសេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចមួយមានភាពរសើបដែលកើតចេញពី អ.វ.ត.ក"[11] ប៉ុន្តែជាការការពារការបំបែកបទចោទទៅតាមការកំណត់ព្រំដែននានា ដែលបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងថា "<u>អាចដំណើរការបានយ៉ាងពិតប្រាកដ</u>"[12]។

៧- លើសពីនេះ សារណាបន្ថែមមានមូលដ្ឋាននៅលើការបង្ហាញខុសជូនអង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿងលេខ០០២/០១។ ជាឧទាហរណ៍ មេធាវីការពារក្តីបានអះអាងថា អង្គជំនុំជម្រះសាលាដំបូង "បានណែនាំដល់ភាគីថា ជាទូទៅ អង្គជំនុំជម្រះមានសិទ្ធិដេញដោលសាក្សីអង្គហេតុតែសំណួរណាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋនានា ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ប៉ុណ្ណោះ។ លើសពីនេះទៀត ភាគីមានសិទ្ធិសួរសំណួរសាក្សីលើអង្គហេតុក្រៅវិសាលភាព

---

[10] **E284/4/5** សារណាបន្ថែម, វាក្យខណ្ឌចំណងជើង IV(ក)។

[11] **E124/5** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យពិចារណាឡើងវិញលើដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, ១១ តុលា ២០១១, ត្រង់កថាខណ្ឌទី៣។

[12] **E163/5/1/4** សារណាឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទិនទៅនឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១, ១៩ វិច្ឆិកា ២០១២, ត្រង់កថាខណ្ឌទី៣១ (សេចក្តីយោងខាងក្នុងត្រូវបានលុបចេញ)។

នៃសំណុំរឿង០០២/០១ ដែលចាំបាច់ដើម្បីកំណត់ទៅលើបញ្ហារចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនង ឬឃាតា"[13]។

៨- តាមពិត ចាប់តាំងពីមានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កាលពីខែកញ្ញា ឆ្នាំ២០១១ មក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់ថា ភ័ស្តុតាងក្នុងសំណុំរឿង០០២/០១ នឹងត្រូវទាក់ទងទៅនឹង មិនត្រឹមតែបទចោទជាក់លាក់នៅក្នុងសវនាការប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវបង្ហាញភ័ស្តុតាងមូលដ្ឋានដែលមានបំណងគាំទ្រដល់បទចោទបន្ថែមណាមួយដែលពេលក្រោយមក អាចនឹងបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ ឬទៅក្នុងសវនាការបន្ថែមណាមួយ ដែលអាចនឹងកើតមានឡើង[14]។ អង្គជំនុំជម្រះសាលាដំបូង ថ្វីបើមានដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី កាលពីខែកញ្ញា ឆ្នាំ ២០១១ ក៏ដោយ ក៏បានណែនាំដល់ភាគីនានាយ៉ាងច្បាស់ នៅមុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីលើភ័ស្តុតាងថា "ជនជាប់ចោទត្រូវប្រឈមនឹងការចោទប្រកាន់ទាំងអស់ ដែលមាននៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ ...ហើយអង្គជំនុំជម្រះរំពឹងថា សវនាការដំណាក់កាលដំបូងនេះនឹងផ្តល់ជាមូលដ្ឋានរួមមួយសម្រាប់បទចោទទាំងអស់ រួមទាំងបទ ចោទនានាដែលអង្គជំនុំជម្រះនឹងលើកយកទៅពិភាក្សាដេញដោលក្នុងសវនាការដំណាក់កាលបន្ទាប់"[15]។ សហព្រះរាជអាជ្ញាបានលើកចំណុចនេះរួចហើយនៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងសេចក្តីថ្លែង ដែលនាំឲ្យមានការយល់ខុសស្រដៀងគ្នានេះ នៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ[16]។

៩- ដូចដែលមានលក្ខណៈច្បាស់លាស់នៅក្នុងសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងខាងលើនេះ ក៏ដូចជានៅក្នុងបញ្ជីកថាខណ្ឌនានាដែលទាក់ទងនឹងសំណុំរឿង០០២/០១[17] ដូច្នោះដែរ ភ័ស្តុតាងស្តីពី

[13] **E284/4/5** សារណាបន្ថែម, ត្រង់កថាខណ្ឌទី៦។

[14] **E124** ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង, ២២ កញ្ញា ២០១១, ត្រង់កថាខណ្ឌទី១(ឃ), ៥។ សូមអានផងដែរ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, ត្រង់កថាខណ្ឌទី៨។

[15] **E131** ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង០០២, ១៨ តុលា ២០១១។

[16] **E284/4/3** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, ១៧ មិថុនា ២០១៣, ត្រង់កថាខណ្ឌទី៩។

[17] **E124/7.3** ឧបសម្ព័ន្ធ, ត្រង់ផ្នែកទី១។

វចនាសម្ព័ន្ធរដ្ឋបាល ការទំនាក់ទំនង និងយោធា គឺមិនមែនជាការលើកលែង "ចំៗ" ទៅនឹងភស្តុតាង ដែលបានកម្រិតថា មេធាវីការពារក្តីនឹងត្រូវធ្វើឲ្យអង្គជំនុំជម្រះនេះជឿជាក់ ក៏ប៉ុន្តែជាភស្តុតាងមួយស្នូលក្នុងចំណោមភស្តុតាងស្នូលជាច្រើនក្នុងសំណុំរឿង០០២/០១។

១០- ចរិកលក្ខណ:ទូលំទូលាយនៃភស្តុតាងជាមូលដ្ឋាននៅក្នុងសំណុំរឿង០០២/០១ ក៏បានពន្លាតផងដែរនូវអត្ថិភាពនៃគោលនយោបាយរបស់ បកក ដែលត្រូវបានចោទប្រកាន់ ដែលមានសហឧក្រិដ្ឋកម្មរួមនៅក្នុងនោះ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានថ្លែងនៅពេលបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០១ ថាអង្គជំនុំជម្រះនឹង "ធ្វើការពិចារណាទៅលើតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ទាក់ទិនទៅនឹង<u>គោលនយោបាយទាំងអស់ដែលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល</u>"[18]។ ថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា "ពីដើមដំបូង អង្គជំនុំជម្រះបានសម្រេចថាភាគីទាំងអស់អាចបង្ហាញភស្តុតាងទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទ ទាក់ទងនឹងគោលនយោបាយនៃរបបខ្មែរក្រហម"[19]។

១១- មេធាវីការពារក្តីធ្លាប់បានដឹងគ្រប់គ្រាន់ហើយថា ប្រធានបទទាំងនេះបានបង្កើតជាផ្នែកមួយនៃកំណត់ហេតុភស្តុតាង សូម្បីតែបានការពារខ្លួនឯងផ្ទាល់នៅត្រង់ចំណុចមួយដែលថា ភស្តុតាងដែលត្រូវបានប្រមូលពាក់ព័ន្ធនឹងទីកន្លែងឧក្រិដ្ឋកម្មនានាដែលមិនបានដាក់បញ្ចូលក្នុងសំណុំរឿង០០២/០១ "អាចត្រូវបានប្រើដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងពេលសម្រេចសាលក្រមមួយ ពិសេសសម្រាប់គោលបំណងវាយតម្លៃចំពោះប្រធានបទជាច្រើន នៅក្នុងសំណុំរឿងលេខ០០២ រួមមាន ប្រវត្តិសាស្ត្រ, វចនាសម្ព័ន្ធ រដ្ឋបាល និងការប្រាស្រ័យទាក់ទងរបស់ បកក និងរបបកម្ពុជាប្រជាធិបតេយ្យ, តួនាទី និងមុខតំណែងរបស់ជនជាប់ចោទ, ក៏ដូចជាការវិវឌ្ឍន៍រីកចម្រើននៃគោលនយោបាយឧក្រិដ្ឋទាំងប្រាំ

---

[18] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១, ត្រង់កថាខណ្ឌទី១១។

[19] **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌទី១១៧។

ដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ <u>ហេតុដូច្នេះ ភ័ស្តុតាងនេះនឹងមិនត្រូវបាត់បង់ តាមបែបណាមួយបានឡើយ</u>”[20]។

១២- ក្នុងការបង្ហាញភ័ស្តុតាងអំពីអត្ថិភាពនៃគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួម យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមានភាពច្បាស់លាស់ណាស់ថា ការអនុវត្តនូវឧក្រិដ្ឋកម្មស្រដៀងៗគ្នានេះ ដោយផ្អែកលើមូលដ្ឋាននៃលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធអាចបង្ហាញជាភ័ស្តុតាងអំពីគោលនយោបាយក្នុងការអនុវត្តនូវឧក្រិដ្ឋកម្មទាំងនោះ។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា “អាចនឹងមានប្រយោជន៍ ក្នុងការបង្ហាញឲ្យឃើញថាការវាយប្រហារត្រូវបានផ្តោតមុខសញ្ញាប្រឆាំងទៅលើប្រជាជនស៊ីវិល ហើយថាការវាយប្រហារនេះ មានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ (ជាពិសេស ការវាយប្រហារក្រោយនេះ) ដើម្បីបង្ហាញថា តាមការពិត គឺមានគោលនយោបាយ ឬផែនការមួយ ប៉ុន្តែអាចមានលទ្ធភាពបង្ហាញភ័ស្តុតាងអំពីអ្វីៗទាំងនេះបាន ដោយយោងទៅលើបញ្ហាផ្សេងទៀត”។ ហេតុនេះ អត្ថិភាពនៃគោលនយោបាយ ឬផែនការណាមួយ អាចមានការទាក់ទងជាក់ស្តែង ប៉ុន្តែមិនមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មតាមច្បាប់ឡើយ”[21]។ នៅក្នុងវនាការរបស់តុលាការត្រូវបានលើកឡើងយោង ដោយមេធាវីការពារក្តីនៅក្នុងសារណាបន្ថែមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងគ្រាន់តែទទួលស្គាល់ថាមានឯកសារមួយចំនួនមានការជាប់ទាក់ទងទៅនឹងទាំងអត្ថិភាព និងទាំងការអនុវត្តគោលនយោបាយ ហើយដែលមេធាវីការពារក្តីបន្តមានសិទ្ធិ និងមានឱកាស ដូចដែលខ្លួនធ្លាប់ធ្វើជារៀងមក ក្នុងការបង្ហាញភ័ស្តុតាង និងអំណះអំណាងដែលទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយសហកម្មឧក្រិដ្ឋកម្មរួម[22]។

១៣- ដោយមានភាពងាយស្រួល ឧទាហរណ៍ដើម្បីបញ្ជាក់ឲ្យឃើញច្បាស់របស់មេធាវីការពារក្តីដែលចោទប្រកាន់អំពីមានកំហុស[23] គឺជាមធ្យោបាយប្រសើរបំផុតសម្រាប់បង្ហាញផងដែរថា អំណះអំណាង

---

[20] **E284/4/3** ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ នួន ជា ជំទាស់នឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសេចក្តីសន្និដ្ឋានតបទៅនឹងចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា, ១៧ មិថុនា ២០១៣, ត្រង់កថាខណ្ឌទី១០។ ដកស្រង់ **E163/5/1/4** ត្រង់កថាខណ្ឌទី៣៥ (សម្រង់សេចក្តី និងការលើកយោង ត្រូវបានលុបចោល) ។

[21] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Dragoljub Kunarac និងគ្នីគ្នា*, សំណុំរឿងលេខ IT-96-23/1-A, សាលដីកាបណ្តឹងសាទុក្ខ, ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០២, កថាខណ្ឌទី៩៨។

[22] ឯកសារលេខ **E1/213.1** សេចក្តីព្រាងប្រតិចារឹក , ចុះថ្ងៃទី២៦ មិថុនា ២០១៣, ទំព័រ៥០។

[23] ឯកសារលេខ **E284/4/5** សារណាបន្ថែម , ត្រង់កថាខណ្ឌទី១៦។

របស់ខ្លួន គឺមិនមានខ្លឹមសារទាំងស្រុង។ មេធាវីការពារក្ដីជំទាស់ថា ការបង្ហាញនូវឯកសារនានាដែលបង្ហាញអំពីតួនាទីរបស់ នួន ជា នៅក្នុងមន្ទីរសន្តិសុខស-២១ គឺមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១នោះទេ ហើយការអះអាងថាការបង្ហាញជូនដែលបានធ្វើឡើង នៅក្នុងតុលាការដោយសហព្រះរាជអាជ្ញា គឺជាការមិនត្រឹមត្រូវត្រង់កម្រិតណាមួយ[24]។ ទោះជាយ៉ាងណាក្ដី ការយោងទៅលើបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីកថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយដែលរួមបញ្ចូលនៅក្នុងសំណុំរឿងលេខ០០២/០១ បង្ហាញថា កថាខណ្ឌទី៨៧៧ និង៨៧៩ ត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះ[25]។ កថាខណ្ឌទាំងនោះពាក់ព័ន្ធនឹង នួន ជា និងតួនាទីរបស់គាត់ចំពោះមន្ទីរស-២១ និងនិយាយដើម្បីខ្លួនឯង ដោយបដិសេធចំពោះអំណះអំណាងរបស់មេធាវីការពារក្ដី៖

កថាខណ្ឌ៨៧៧. នៅក្នុងកិច្ចសម្ភាសន៍ជាច្រើនដែលបានធ្វើឡើង ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា បានពន្យល់ថា មុនឆ្នាំ១៩៧៩ គាត់មិនបានដឹងពីមន្ទីរស-២១នោះទេ ហើយប្រសិនបើមានឯកសារណាមួយដាក់បន្ទុកលើរូបគាត់ ឯកសារនោះគឺជាឯកសារដែលគេរៀបចំឡើងតែប៉ុណ្ណោះ។ នួន ជា បានបន្ថែមទៀតថា ឌុច ធ្លាប់ធ្វើការនៅក្រសួងការពារជាតិ និងសន្តិសុខផ្ទៃក្នុង ដែលមាន សុន សេន ជាអ្នកទទួលខុសត្រូវ។ ទោះបីជាយ៉ាងណាក៏ដោយ មានភ័ស្តុតាងយ៉ាងច្បាស់បានបង្ហាញថា នួន ជា ទទួលបន្ទុកគ្រប់គ្រងលើមន្ទីរសន្តិសុខស-២១ និងការដ្ឋានស-២៤(ព្រៃស)របស់មន្ទីរស-២១ ចាប់តាំងពីការបង្កើតមន្ទីរស-២១ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។

កថាខណ្ឌ៨៧៩. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ សុន សេន បានចាកចេញពីភ្នំពេញទៅកាន់សមរភូមិមុខ នៅក្នុងជម្លោះជាមួយប្រទេសវៀតណាម ហើយ នួន ជា បានហៅ ឌុច ឲ្យមកការិយាល័យរបស់គាត់នៅពុទ្ធ

[24] ឯកសារលេខ **E284/4/5** សារណាបន្ថែម , ត្រង់កថាខណ្ឌទី១៦។

[25] ឯកសារលេខ **E124/7.3** ឧបសម្ព័ន្ធ, ត្រង់ទំព័រ១។

សាសនាបណ្ឌិត្យ។ ចាប់ពីពេលនោះមក ឌុច យល់បានថា គាត់ត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា ដែលក្លាយជាថ្នាក់លើផ្ទាល់របស់គាត់។ ឌុច បញ្ជាក់ថា នួន ជា បានប្រាប់គាត់ថា "*ប្រធាននៃស-២១ មិនមែនខ្ញុំទេ គឺគាត់ នួន ជា ជាប្រធាន*"។ ទោះបីជាត្រូវរាយការណ៍ផ្ទាល់ទៅ នួន ជា ឌុច នៅតែរក្សាទំនាក់ទំនងជាមួយនឹង សុន សេន តាមរយៈទូរស័ព្ទ ជារៀងរាល់ពីរសប្តាហ៍ម្តង ឬមួយខែម្តង។ ថ្វីបើ ឌុច ឈប់ផ្ញើចម្លើយសារភាពទៅ សុន សេន ទៀតហើយក៏ដោយ សុន សេន នៅតែចូលរួមតាមដានសកម្មភាពការងាររបស់មន្ទីរស-២១ដដែល។ ឌុច យល់ថា សុន សេន នៅតែចាត់ទុកខ្លួនគាត់ជាថ្នាក់លើរបស់គាត់(ឌុច)[26]។

១៤- ហេតុនេះ ការអះអាងរបស់ជនជាប់ចោទដែលថា សិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះត្រឹមត្រូវរបស់ខ្លួន កំពុងតែត្រូវបានរំលោភដោយការបង្ហាញភស្តុតាងដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ០០២/០១ គឺជាការខុស។ សារណាបន្ថែមគឺមិនមានខ្លឹមសារទេ ហើយគួរតែបដិសេធចោល។

## III. សេចក្តីសន្និដ្ឋាន

១៥- អាស្រ័យហេតុដូចបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តាបដិសេធនូវសារណាបន្ថែមនេះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

[26] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០, ត្រង់កថាខណ្ឌទី៨៧៧ និង៨៧៩ ( ការលើកសម្អាងផ្ទៃក្នុងត្រូវបានលុបចោល)។